*សេចក្តីព្រាងទី ៤ នាយកដ្ឋាននីតិកម្ម ក្រសួងអប់រំ យុវជន និងកីឡា*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

# គោលនយោបាយ

# ស្តីពី

# កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំ

library.ncdd.gov.kh
015491

បានទទួលការឯកភាពពីថ្នាក់ដឹកនាំក្រសួង

ក្នុងកិច្ចប្រជុំនាថ្ងៃទី ខែ ឆ្នាំ២០១.....

**រៀបចំដោយនាយកដ្ឋាននីតិកម្ម**

## ១-សេចក្ដីផ្ដើម

ឯកសារគោលនយោបាយនេះកំណត់នូវចក្ខុវិស័យ គោលដៅ វត្ថុបំណង យុទ្ធសាស្ត្រ និងសកម្មភាពចាំបាច់នានាក្នុងដំណើរការនៃការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំនៃព្រះរាជាណាចក្រកម្ពុជា។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំបាននឹងកំពុងអនុវត្តនៅក្នុងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍនានាតាមទម្រង់ និងបែបផែនផ្សេងៗគ្នា។ ជាទូទៅប្រទេសដែលជាសមាជិកនៃអង្គការសហប្រតិបត្តិការអភិវឌ្ឍសេដ្ឋកិច្ច (OECD) សុទ្ធសឹងជាប្រទេសដែលមានវិមជ្ឈការខ្លាំងលើការគ្រប់គ្រង ដោយផ្ដល់នូវអំណាចដល់អាជ្ញាធរមូលដ្ឋាន និងគ្រឹះស្ថានសិក្សាសាធារណៈនូវការទទួលខុសត្រូវយ៉ាងទូលំទូលាយលើមុខងារគ្រប់គ្រងការអប់រំ។ ជាក់ស្ដែងមុខងារមួយចំនួនក្នុងវិស័យអប់រំ ត្រូវបានផ្ដល់ស្វ័យភាពដល់គ្រឹះស្ថានសិក្សាសាធារណៈរួមមាន៖ ការសាងសង់ និងថែទាំគ្រឹះស្ថានសិក្សាសាធារណៈ ការជ្រើសរើស និងបញ្ចប់ការកិច្ចគ្រូបង្រៀន ការជ្រើសរើសអ្នកគ្រប់គ្រង និងដឹកនាំ និងបុគ្គលិករដ្ឋបាលនានា ការអភិវឌ្ឍកម្មវិធីសិក្សា និងគោលនយោបាយនានាដើម្បីឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចសង្គមក្នុងបរិបទតំបន់នីមួយៗ។ អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋចូលរួមយ៉ាងសកម្មក្នុងអភិបាលកិច្ចសាលារៀន និងប្រកបដោយតម្លាភាព និងគណនេយ្យភាពខ្ពស់ក្នុងការកំណត់របបហិរញ្ញវត្ថុសម្រាប់ការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។

នៅក្នុងកម្រិតតំបន់ ដំណើរការនៃការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំក្នុងបណ្ដាប្រទេសសមាជិកអាស៊ានទាំង១០ និងប្រទេសទីម័រ មានភាពផ្សេងៗគ្នា។ ជាក់ស្ដែងប្រទេសដែលមានសេដ្ឋកិច្ចអភិវឌ្ឍជឿនលឿន ដូចជាប្រទេសសិង្ហបុរី បានអនុវត្តប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការពេញលេញទាំងផ្នែកបច្ចេកទេស និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ដូចជាគ្រឹះស្ថានសិក្សាសាធារណៈ។ មានប្រទេសមួយចំនួនទៀតដែលជាសមាជិកអាស៊ានបាននឹងកំពុងអនុវត្តនូវកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការផ្ទេរមុខងារឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថាសិក្សាសាធារណៈសម្រាប់វិស័យអប់រំ ក្នុងនោះ មានប្រទេសឥណ្ឌូនេស៊ី បានចាប់ផ្ដើមធ្វើវិមជ្ឈការមុខងារពីថ្នាក់ជាតិឱ្យទៅដល់រដ្ឋបាលថ្នាក់ស្រុក នៅក្នុងឆ្នាំ២០០៣។ ការផ្ទេរមុខងារនេះ រួមមានទាំងការធ្វើវិមជ្ឈការអភិបាលកិច្ច ចាប់ពីកម្រិតសាលាបឋមសិក្សា ដល់មធ្យមសិក្សា លើប្រព័ន្ធគ្រប់គ្រងតាមបែបសាលារៀន (School-based management)។

ក្នុងព្រះរាជាណាចក្រកម្ពុជាកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យអប់រំ ជាផ្នែកមួយនៃការធ្វើកំណែទម្រង់របស់រាជរដ្ឋាភិបាលដើម្បីពង្រឹងអភិបាលកិច្ចល្អ។ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដែលបានរៀបចំដោយរាជរដ្ឋាភិបាល បានកំណត់នូវគោលដៅរួមក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និងភាពសក្តិសិទ្ធលើការផ្ដល់សេវា

របស់រដ្ឋបាលសាធារណៈដើម្បីទទួលបានការអភិវឌ្ឍដោយចីរភាព ពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច និងផ្តល់នូវកាលានុវត្តភាពស្មើៗគ្នាចំពោះប្រជាជនគ្រប់រូប។ ការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ គឺជាការចូលរួមចំណែកលើកកម្ពស់ឱ្យមានការចូលរួមពីប្រជាជន ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំ ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន ពង្រឹងការទទួលសេវាអប់រំសាធារណៈ និងលើកទឹកចិត្តដល់មាតាបិតា អាណាព្យាបាល និងសហគមន៍ អោយចូលរួមកាន់តែសកម្មក្នុងអភិបាលកិច្ចសាលារៀន។

ឯកសារគោលនយោបាយមួយចំនួនរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់ជាមូលដ្ឋានដ៏សំខាន់ក្នុងការកំណត់នូវចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ កំណែទម្រង់នេះគឺជាផ្នែកមួយយ៉ាងសំខាន់នៃកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលជាកម្មវិធីកំណែទម្រង់មួយក្នុងចំណោមកំណែទម្រង់សំខាន់ៗទាំង ៤ ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

នៅខែមិថុនា ឆ្នាំ២០០៥ រាជរដ្ឋាភិបាលបានអនុម័តនូវក្របខ័ណ្ឌយុទ្ធសាស្ត្រ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការសំដៅបង្កើតឡើងនូវប្រព័ន្ធអភិបាលកិច្ចល្អនៅថ្នាក់ក្រោមជាតិដោយឈរ លើគោលការណ៍ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋានជំរុញកិច្ចអភិវឌ្ឍមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្រ។កម្មវត្ថុដ៏សំខាន់ដើម្បីសម្រេចគោលដៅនេះ តម្រូវឱ្យមានការផ្ទេរអំណាច ការទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្ស ដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ នៅក្នុងឆ្នាំ២០០៨ ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានបង្កើតឡើងដើម្បីកែសម្រួលប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលក្នុងគោលបំណងសម្របសម្រួលកិច្ចការរដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងក្រោមជាតិ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍនៅមូលដ្ឋាន។ ផ្អែកលើច្បាប់នេះ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិអំណាចក្នុងការបំពេញតួនាទីដែលត្រូវបានប្រគល់ឱ្យនៅក្នុងអាណាត្តិរបស់ខ្លួន។ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានកំណត់អំពីគោលបំណង វិសាលភាពក្នុងការអនុវត្តកម្មវិធីនៅក្នុងសមាសភាពនីមួយៗ សំដៅសម្រេចឱ្យបាននូវគោលដៅនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

រាជរដ្ឋាភិបាលបានចាត់ទុកវិស័យអប់រំ ជាវិស័យអាទិភាពមួយដ៏សំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស ដែលជាកត្តាសំខាន់ក្នុងការធ្វើឱ្យសេដ្ឋកិច្ចចម្រើនលូតលាស់ប្រកបដោយចីរភាព ឈានទៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺជាគោលនយោបាយដ៏សំខាន់មួយដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (**ឆ្នាំ២០១៤-២០១៨**???)( ការធ្វើវិមជ្ឈការលើការអភិវឌ្ឍន៍ស្ថាប័ន និងសមត្ថភាព)

កន្លងមកក្រសួងអប់រំ យុវជន និងកីឡាបានធ្វើប្រតិភូកម្មនូវមុខងារមួយចំនួនជូនដល់ថ្នាក់ក្រោមជាតិរបស់ខ្លួន ដែលរួមមានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សាសាធារណៈ ដើម្បីអនុវត្តមុខងារទាំងនេះក្នុងនាមក្រសួង។ ប៉ុន្តែកន្លងមកមិនក្រសួងមិនបានធ្វើប្រតិភូកម្មនូវមុខងារជូនដល់ក្រុមប្រឹក្សាមូលដ្ឋានទេ។

ដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ បង្វិតសេវាអប់រំឱ្យកៀកជាមួយប្រជាជន កាត់បន្ថយនីតិវិធីរដ្ឋបាលស្មុគស្មាញ និងអនុវត្តឱ្យបានសម្រេចតាមការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលលើការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ស្របតាមក្របខណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំកសាងគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំ សំដៅលើកកម្ពស់ការអនុវត្តកម្មវិធីកំណែទម្រង់វិស័យអប់រំ និងជំរុញឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធីកំណែទម្រង់នេះឱ្យមានប្រសិទ្ធភាព។

## ២-ចក្ខុវិស័យ

គោលនយោបាយ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំមានចក្ខុវិស័យធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈ ឆ្លើយតបទៅនឹងតម្រូវការសង្គម និងតម្រូវការផ្សេងៗនៃអ្នកសិក្សា ប្រកបដោយប្រសិទ្ធិភាព ភាពសក្តិសិទ្ធ និងភាពម្ចាស់ការ ដោយផ្តោតជាពិសេសលើលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌។

## ៣-គោលបំណង

គោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំមានគោលបំណងពង្រឹងនូវស្វ័យភាព និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈក្នុងការផ្តល់សេវាអប់រំ ។

## ៤-គោលដៅ

គោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំមានគោលដៅ៖

- កំណត់អំពីទិសដៅជាយុទ្ធសាស្ត្រស្របតាមគោលដៅរយៈពេលមធ្យម និងកម្មវិធីនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៤-២០១៨ និងគោលដៅរយៈពេលវែងដែលត្រូវបានកំណត់ដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប)
- ធានាថាមុខងារ ធនធានហិរញ្ញវត្ថុ និងធនធានមនុស្សត្រូវបានរៀបចំជាបញ្ជីវិភាគមុខងារ និងពិនិត្យមើលឡើងវិញដើម្បីផ្ទេរជូនទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថាន

សិក្សាសាធារណៈ និងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ (ស្នើឱ្យមានការពិភាក្សាបន្ថែម)

- ធានាថាការគ្រប់គ្រងដោយផ្អែកលើសាលារៀន ត្រូវបានអនុវត្តនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ

## ៥-យុទ្ធសាស្ត្រ

### ៥.១- អភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ

- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងយន្តការនានាស្របតាមក្របខ័ណ្ឌនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាពដោយមានកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធសំខាន់ៗ
- ធ្វើឱ្យប្រសើរឡើង និងពន្លឿនការអនុវត្តគោលនយោបាយ ក្របខ័ណ្ឌគតិយុត្ត និងយន្តការពាក់ព័ន្ធនានាដែលមានស្រាប់ និងយន្តការថ្មីៗ
- កសាងផែនការសកម្មភាព និងគម្រោងនានាសម្រាប់អនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ ដោយកំណត់ពីសូចនាករ សកម្មភាពជាក់លាក់ ក្របខ័ណ្ឌពេលវេលា ធនធាន និងអង្គភាពទទួលខុសត្រូវ។

### ៥.២- ការអភិវឌ្ឍស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- ពិនិត្យមើល និងពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងវិស័យអប់រំថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាល ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស
- អភិវឌ្ឍរចនាសម្ព័ន្ធសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមសាលាមធ្យមសិក្សានានា
- លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់ទំនើបកម្ម និងវិមជ្ឈការនៃប្រព័ន្ធរដ្ឋបាល និងត្រួតពិនិត្យ
- ជំរុញអង្គភាពជំនាញពាក់ព័ន្ធទាំងអស់ក្នុងវិស័យអប់រំ ចូលរួមនិងសហការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំ
- រៀបចំនិងអនុវត្តយន្តការ សម្របសម្រួលរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ក្រោមជាតិវិស័យអប់រំ
- អនុវត្តយន្តការសម្របសម្រួលរវាង កិច្ចសហការរវាងក្រសួងអប់រំ យុវជន និងកីឡាជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តមុខងារក្រោមអាណត្តិទូទៅ

- សហការជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ដើម្បីអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ពង្រឹងប្រព័ន្ធគ្រប់គ្រងតាមបែបប្រជាធិបតេយ្យផ្អែកលើគោលការណ៍អភិបាលកិច្ចល្អនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**៥.៣- ការផ្ទេរមុខងារ និងធនធានវិស័យអប់រំឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

- រៀបចំដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានវិស័យអប់រំឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពថ្នាក់ក្រោមជាតិប្រកបដោយសនិទានភាព ភាពជាលក្ខណៈប្រព័ន្ធ សម្របសម្រួល ពិគ្រោះយោបល់ ផែនការ តម្លាភាព និងសមធម៌។
- បង្កើតក្របខ័ណ្ឌគតិយុត្តិស្តីពី ការផ្ទេរមុខងារ និងធនធានដោយពិគ្រោះយោបល់ជាមួយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
- ធានានូវកិច្ចសម្របសម្រួលនិងសហការរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈ
- លើកទឹកចិត្តនិងចង្អុលបង្ហាញដល់ក្រុមប្រឹក្សាដើម្បីអនុវត្តមុខងារជាជម្រើស
- ធានាថាការផ្ទេរមុខងារវិស័យអប់រំឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវភ្ជាប់ជាមួយនឹង ធនធានមនុស្ស និងហិរញ្ញវត្ថុ
- កំណត់អំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រសួងអប់រំ យុវជន និងកីឡាបន្ទាប់ពីមានការផ្ទេរមុខងារ។

**៥.៤- ការគ្រប់គ្រងធនធានមនុស្ស**

- រៀបចំ និងកែសម្រួលឡើងវិញនូវប្រព័ន្ធគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ
- វាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈ
- រៀបចំក្របខ័ណ្ឌគតិយុត្តសម្រាប់ធ្វើការផ្ទេរបុគ្គលិកអប់រំជូនរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមទំហំនៃមុខងារដែលត្រូវផ្ទេរ និងប្រភេទក្រុមប្រឹក្សាដែលត្រូវទទួល
- សហការជាមួយនឹង គ.ជ.អ.ប និងក្រសួងមុខងារសាធារណៈក្នុងការរៀប ចំលក្ខន្តិកៈដោយឡែកសម្រាប់គ្រប់គ្រងវិស័យអប់រំ អោយស្របជាមួយនឹងលក្ខន្តិកៈបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- ផ្តល់ស្វ័យភាពដល់គ្រឹះស្ថានសិក្សាសាធារណៈក្នុងការចាត់ចែង និងប្រើប្រាស់ធនធានមនុស្ស។

៥.៥- ការគ្រប់គ្រងធនធានហិរញ្ញវត្ថុ

- ធ្វើការសិក្សាលើការប្រើប្រាស់ធនធានហិរញ្ញវត្ថុ រៀបចំក្របខ័ណ្ឌគតិយុត្តសម្រាប់ធ្វើការផ្ទេរធនធានហិរញ្ញវត្ថុវិស័យអប់រំជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមទំហំនៃមុខងារដែលត្រូវផ្ទេរ និងប្រភេទក្រុមប្រឹក្សាដែលត្រូវទទួល
- សហការជាមួយនឹង គ.ជ.អ.ប និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីរៀបចំ និងកែសម្រួលរបបហិរញ្ញវត្ថុ និងការវិភាជន៍ថវិកាវិស័យអប់រំនៅពេលមានការផ្ទេរមុខងារ
- ធ្វើវិមជ្ឈការ និងវិសហមជ្ឈការការប្រើប្រាស់ថវិកាវិស័យអប់រំឱ្យទៅដល់ថ្នាក់ក្រោមជាតិ នៅពេលមានការផ្ទេរមុខងារដល់ថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈ
- ធ្វើវិមជ្ឈការការកសាងផែនការហិរញ្ញវត្ថុដល់ថ្នាក់ក្រោមជាតិវិស័យអប់រំ ស្របជាមួយនឹងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ផ្តល់ស្វ័យភាពដល់គ្រឹះស្ថានសិក្សាសាធារណៈលើការកសាងផែនការ និងការប្រើប្រាស់ថវិកាប្រតិបត្តិ
- ស្វែងរកការគាំទ្រផ្នែកហិរញ្ញវត្ថុ ពីរដ្ឋាភិបាលកម្ពុជា និងរដ្ឋសភាជាតិ ដើម្បីអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំ។
- លើកកម្ពស់ការចូលរួមពីដៃគូអភិវឌ្ឍន៍ និងការប្រមូលនូវធនធានហិរញ្ញវត្ថុ

៥.៦- ការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- កសាងផែនការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ និងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការធ្វើបច្ចុប្បន្នភាពលើផែនការគោលអភិវឌ្ឍសមត្ថភាពរបស់ក្រសួង អប់រំ យុវជន និងកីឡា
- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងជំនាញសម្រាប់បុគ្គលិកថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចាប់ពីបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈ
- ផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈនៅពេលមានការផ្ទេរមុខងារ
- កសាងសមត្ថភាពមន្ត្រីជំនាញដែលទទួលខុសត្រូវលើការងារអប់រំវិជ្ជាជីវៈគ្រប់កម្រិត និងគ្រប់ជំនាញ
- អភិវឌ្ឍសមត្ថភាពដល់គ្រឹះស្ថានសិក្សាសាធារណៈដើម្បីជំរុញស្វ័យភាពលើការងារគ្រប់គ្រង។

៥.៧- ស្វ័យភាពគ្រឹះស្ថានសិក្សាសាធារណៈ

- កំណត់តំបន់សម្រាប់ការផ្ដល់ស្វ័យភាពដល់គ្រឹះស្ថានសិក្សាសាធារណៈ ដោយប្រឹក្សាយោបល់ជាមួយនាយកដ្ឋានបច្ចេកទេសពាក់ព័ន្ធនានា
- រៀបចំយន្តការក្នុងការផ្ដល់ស្វ័យភាពលើការងារគ្រប់គ្រងដល់គ្រឹះស្ថានសិក្សាសាធារណៈជាបន្តបន្ទាប់
- ពិនិត្យមើលឡើងវិញ និងផ្ដល់សិទ្ធិអំណាចដល់គណៈកម្មការទ្រទ្រង់សាលារៀន និងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ
- ផ្ដល់ការអភិវឌ្ឍសមត្ថភាពដល់គណៈកម្មការទ្រទ្រង់សាលារៀន និងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ ដើម្បីអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសាលារៀន (SBM)
- រៀបចំឡើងវិញនូវរចនាសម្ព័ន្ធ តួនាទី និង ភារកិច្ចគ្រឹះស្ថានសិក្សា ស្របតាមរចនាសម្ព័ន្ធនៃការគ្រប់គ្រងផ្អែកលើសាលារៀន
- លើកកម្ពស់ការចូលរួមរបស់សហគមន៍ ក្នុងដំណើរការនៃការអភិវឌ្ឍសាលារៀនប្រកបដោយតម្លាភាព និងសមធម៌តាមរយៈគោលការណ៍អភិបាលកិច្ចល្អ
- រៀបចំឡើងវិញនូវប្រព័ន្ធនៃការសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈ។

៥.៨- ការបញ្ជ្រាបយេនឌ័រ

- ធានាឱ្យមានការចូលរួមដោយស្មើភាពរវាងបុរស និងនារីក្នុងដំណើរការនៃការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ធានាឱ្យបាននូវសមភាពយេនឌ័រ នៃការទទួលបានផលប្រយោជន៍ពីការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ធានាអោយមានភាពជាតំណាងពីជនងាយរងគ្រោះ និងជនជាតិដើមភាគតិច
- ធានាថាជនងាយរងគ្រោះ និងជនជាតិដើមភាគតិចទទួលបាននូវឱកាស និងផលប្រយោជន៍ស្មើៗគ្នាពីការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

## ៦- ផែនការសកម្មភាព

៦.១- ការបង្កើតយន្តការ

- ពង្រឹងក្រុមការងារសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រចាំក្រសួងអប់រំ
- ពង្រឹងអនុក្រុមការងារបច្ចេកទេសកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការសម្រាប់វិស័យអប់រំ

- រៀបចំ និងបង្កើតលេខាធិការដ្ឋានឱ្យមានរចនាសម្ព័ន្ធច្បាស់លាស់ និងថវិកាគាំទ្រដំណើរការនៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការវិស័យអប់រំ

៦.២- ការបង្កើតក្របខ័ណ្ឌគតិយុត្ត

- ក្រុមការងារសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិប្រចាំក្រសួងអប់រំ យុវជន និងកីឡាអនុក្រុមការងារបច្ចេកទេសកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការសម្រាប់វិស័យអប់រំ និងលេខាធិការដ្ឋានកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំត្រូវបង្កើតដោយសេចក្តីសម្រេចរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងអប់រំ យុវជន និងកីឡាត្រូវធ្វើការពិនិត្យមើលឡើងវិញនូវរចនាសម្ព័ន្ធ តួនាទី ភារកិច្ច មុខងារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិៈ
    - កែសម្រួលអនុក្រឹត្យលេខ៨៨អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ស្តីពីការរៀបចំ និងប្រតិបត្តិការទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
    - កែសម្រួលសេចក្តីណែនាំលេខ៣៧៦៧ អយក.សណន ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីមុខងារ ភារកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ក្រុង
    - កែសម្រួលសេចក្តីណែនាំលេខ៣០ អយក.សណន ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ស្តីពីតួនាទីភារកិច្ចរបស់គណៈកម្មការទ្រទ្រង់សាលារៀន
    - រៀបចំលិខិតបទដ្ឋានគតិយុត្ត គាំទ្រការផ្ទេរមុខងារ និងធនធានវិស័យអប់រំ យុវជន និងកីឡាឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
    - រៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គាំទ្រការវិភាជន៍ធនធានឱ្យទៅដល់ថ្នាក់ក្រោមជាតិវិស័យអប់រំ
- ពិនិត្យមើលឡើងវិញ និងកែសម្រួលរាល់លិខិតបទដ្ឋានគតិយុត្តក្នុងវិស័យអប់រំ ដើម្បីគាំទ្រការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

៦.៣- ដំណើការនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

- រៀបចំរបាយការណ៍ស្តីពីបញ្ជីវិភាគមុខងារវិស័យអប់រំ
- ពិនិត្យមើលឡើងវិញនូវមុខងារវិស័យអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិគ្រប់កម្រិត ដើម្បីកំណត់មុខងារធ្វើវិមជ្ឈការ និងវិសហមជ្ឈការមុខងារដល់កម្រិតថ្នាក់ក្រោមជាតិ
- រៀបចំផែនការសកម្មភាពសម្រាប់ផ្ទេរមុខងារ និងធនធានវិស័យអប់រំឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

- វិភាគស្ថានភាពសមត្ថភាព និងធនធាននៃរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍សមត្ថភាពធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស

### ៦.៤- ការគាំទ្រហិរញ្ញវត្ថុ

- ការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំត្រូវប្រើប្រាស់ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា
- ថវិកាបានមកពីដៃគូអភិវឌ្ឍ ឬ អង្គការជាតិ និងអន្តរជាតិជាថវិកាសម្រាប់ដំណើរការ គម្រោង ឬ គាំទ្រសកម្មភាពណាមួយតាមគោលដៅរបស់ដៃគូអភិវឌ្ឍ

### ៦.៥- ការបណ្ដុះបណ្ដាលធនធានមនុស្ស

- ក្រសួងអប់រំ យុវជន និងកីឡាត្រូវរៀបចំផែនការអភិវឌ្ឍសមត្ថភាពស្របតាមតម្រូវការបណ្ដុះបណ្ដាលផុសចេញពីការផ្ទេរមុខងារកម្រិតថ្នាក់ក្រោមជាតិ។ ផែនការអភិវឌ្ឍន៍សមត្ថភាពត្រូវផ្សារភ្ជាប់ជាមួយនឹងផែនការគោលអភិវឌ្ឍសមត្ថភាព សម្រាប់ការអភិវឌ្ឍន៍សមត្ថភាពវិស័យអប់រំ ២០១១ ២០១៥
- បណ្ដុះបណ្ដាលជំនាញបច្ចេកទេសស្ដីពីវិមជ្ឈការ និងវិសហមជ្ឈការ ភាពជាអ្នកដឹកនាំ ការរៀបចំផែនការ ការគ្រប់គ្រងហិរញ្ញវត្ថុ ការវិភាគទិន្នន័យ ជំនាញបច្ចេកទេសដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិវិស័យអប់រំ

### ៦.៦- ដំណើរការអនុវត្តគម្រោង

ការរៀបចំផែនការអនុវត្តរយៈពេលមធ្យម និងវែងដោយមានការពិគ្រោះយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ ផែនការអនុវត្តរយៈពេលមធ្យម និងវែងមានដំណាក់កាលដូចខាងក្រោម៖

- ផែនការអនុវត្ត ៣ឆ្នាំ ២០១១-២០១៤
- ផែនការអនុវត្ត ៣ ឆ្នាំ ២០១៥-២០១៧
- ផែនការអនុវត្ត ៤ឆ្នាំ ២០១៨-២០២០

## ៧- ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ

ដើម្បីឱ្យគោលនយោបាយនេះ មានវិសាលភាពអនុវត្តស្របតាមគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល ចាំបាច់ត្រូវមានប្រព័ន្ធពិនិត្យតាមដានវាយតម្លៃ ការពិនិត្យឡើងវិញ និងសំណើកែលម្អការអនុវត្តផ្ដោតលើ៖

- គោលដៅ និងយុទ្ធសាស្ត្រនៃគោលនយោបាយ ស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំ
- សូចនាករ នៃផែនការសកម្មភាព ស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំ

- លទ្ធផលដែលទទួលបានធៀបទៅនឹងគោលដៅ
- ការចូលរួមរបស់ភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិវិស័យអប់រំ
- ផលប្រយោជន៍នៃភាគីពាក់ព័ន្ធទទួលបានពីការអនុវត្តគោលនយោបាយ។

## ៨- សន្និដ្ឋាន

គោលនយោបាយ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំទទួលស្គាល់ពីបំណងប្រាថ្នា តម្រូវការ និងលក្ខខណ្ឌរបស់ប្រជាជនកម្ពុជា។ ឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើត ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រមួយចំនួន ដើម្បី លើកកម្ពស់ ការអភិវឌ្ឍន៍ប្រជាធិបតេយ្យ និងកម្រិតជីវភាពរស់នៅរបស់ប្រជាជន តាមរយៈលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំ ។

ក្រសួងសង្ឃឹម និងជឿជាក់ថា អង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល សហគមន៍នឹងចូលរួមចំណែកលើកកម្ពស់អនុវត្ត និងគាំទ្រគោលនយោបាយ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំឱ្យបានជោគជ័យ។

**សន្ទានុក្រម**

- **ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ** (Democratic Development):សំដៅលើការអភិវឌ្ឍដែលដំណើរការដោយមានលក្ខណៈ: (១) ភាពជាតំណាងសាធារណៈ (២)ស្វ័យភាពរបស់មូលដ្ឋាន (៣)ការពិគ្រោះយោបល់ និងការចូលរួម (៤) ការឆ្លើយតប និងគណនេយ្យភាព (៥)ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន (៦)ការលើកស្ទួយសមធម៌ (៧)តម្លាភាព និងសុចរិតភាព និង(៨) វិធានការប្រឆាំងអំពើពុករលួយ និងរំលោភអំណាច
- **ការលើក កម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន** (Promote of Life Quality of the Local Residents): សំដៅលើកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើត និងធ្វើឱ្យមាននិរន្តរភាពនូវបរិយាកាសមួយប្រកបដោយសន្តិភាព សុវត្ថិភាព និងសុខុមាលភាព លើកកម្ពស់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច និងលើកកម្ពស់ផាសុកភាព និងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន។
- **ការផ្ទេរមុខងារ** (Transfer of function): សំដៅលើការប្រគល់ ឬ ការធ្វើប្រតិភូកម្មនូវមុខងារទៅឱ្យរដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនូវធនធាន និងសមត្ថភាព។
- **ការអភិវឌ្ឍស្ថាប័ន** (Institutional Development): សំដៅលើការបង្កើតរចនាសម្ព័ន្ធ ប្រព័ន្ធ នីតិវិធីក្រម ឬ និយាមការងារ និងការអភិវឌ្ឍសមត្ថភាពរបស់ស្ថាប័នណាមួយ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ។
- **វិស័យអប់រំ**(Education sector): សំដៅដល់សំណុំនៃសកម្មភាពទាំងឡាយ ដែលពាក់ព័ន្ធនឹងការងារអប់រំ យុវជន និងកីឡា
- **ការលើកស្ទួយសមធម៌** (Promotion of Equity): មានន័យថាការគិតគូរ និងយកចិត្តទុកដាក់ជាពិសេសទៅលើតម្រូវការខុសៗគ្នារបស់ស្ត្រី បុរស យុវជន និងកុមារ ព្រមទាំងតម្រូវការខុសៗ

គ្នារបស់ក្រុមជនងាយរងគ្រោះ រាបបញ្ចូលទាំងប្រជាពលរដ្ឋក្រីក្រ និងជនជាតិដើមភាគតិច។

- **ការពិគ្រោះយោបល់ និងការចូលរួម** (Consultation and Participation):មានន័យថាជាដំណើរការនៃការអនុវត្តការងារ និងការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ដែលក្រុមប្រឹក្សាត្រូវជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងលើកទឹកចិត្ត និងសម្របសម្រួលឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន នៅគ្រប់ផ្នែកទាំងអស់នៃអភិបាលកិច្ច ដើម្បីស្វែងយល់ និងឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ។
- **ការធ្វើប្រតិភូកម្ម ឬ ការធ្វើវិសហមជ្ឈការមុខងារ** (Delegation of Function):សំដៅលើការផ្ទេរនូវមុខងារ ការទទួលខុសត្រូវ សិទ្ធិអំណាច និងឆន្ទានុសិទ្ធិទៅឱ្យថ្នាក់ក្រោមជាតិតាមវិស័យ ឬរដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង និងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្មនៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្ម។
- **ការប្រគល់ ឬ ការធ្វើវិមជ្ឈការមុខងារ** (Assignment of Function):សំដៅលើការផ្ទេរភាពជាម្ចាស់នៃមុខងារ ការទទួលខុសត្រូវ សិទ្ធិអំណាច និងឆន្ទានុសិទ្ធិទាំងអស់ដែលចាំបាច់ ទៅឱ្យរដ្ឋបាលនីមួយៗ នៃរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង និងអនុវត្តមុខងារ។
- **រដ្ឋបាលថ្នាក់ក្រោមជាតិ** (Sub-National Administration):សំដៅលើរដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដែលរដ្ឋបាលនីមួយៗមានក្រុមប្រឹក្សាមួយជាតំណាង។
- **មុខងារ** (Function): សំដៅលើសកម្មភាពរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហគមន៍ តាមរយៈទង្វើប្រកបដោយនិរន្តរភាព ហើយផ្តល់ផលប្រយោជន៍ដល់សហគមន៍។ ឧទាហរណ៍៖ សហគមន៍ត្រូវការទឹកស្អាតសម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន។ រដ្ឋបាលណាមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលយកនូវមុខងារក្នុងការផ្តល់នូវទឹកស្អាតដល់សហគមន៍ប្រើប្រាស់ជាប្រចាំ តាមរយៈការបង្កើតហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត ព្រមទាំងយន្តការសម្រាប់គ្រប់គ្រង ថែទាំ ត្រួតពិនិត្យគុណភាពទឹក។ល។
- **សេវាសាធារណៈ** (public Service): រាល់សកម្មភាពទាំងឡាយដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ចក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ។ ស្ថាប័នមានសមត្ថកិច្ចក្នុងន័យនេះសំដៅលើស្ថាប័នរដ្ឋ ឬ ភ្នាក់ងាររដ្ឋ ឬ អាជ្ញាធរគ្រប់លំដាប់ថ្នាក់របស់រដ្ឋដែលបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន។ ស្ថាប័នទទួលសមត្ថកិច្ច ក្នុងន័យនេះសំដៅលើផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបានសិទ្ធិ និងភារកិច្ចពីរដ្ឋ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់រដ្ឋ ឬ ភ្នាក់ងាររដ្ឋ។